| ៣២- | លោកស្រី អន សុខា | គ្រូបង្រៀន | សាលាបឋមសិក្សាអូររអិល | សាលាក្រៅ |
| ៣៣- | លោកស្រី លី មុំ | គ្រូបង្រៀន | សាលាបឋមសិក្សាសាលាក្រៅ | សាលាក្រៅ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ៦ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៥០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

| | | | |
|---|---|---|---|
| ១- លោកវរសេនីយ៍ទោ | **ឆាយ សុខា** | អត្តលេខ | ០១៧៤៧ |
| ២- លោកវរសេនីយ៍ទោ | **មាយ សំអួន** | អត្តលេខ | ០៣៤៤៩ |
| ៣- លោកវរសេនីយ៍ទោ | **ម៉ៅ លីម** | អត្តលេខ | ០៨៥៣១ |
| ៤- លោកវរសេនីយ៍ទោ | **ហៀង ស៊ីថា** | អត្តលេខ | ១៥៩២៦ |
| ៥- លោកវរសេនីយ៍ទោ | **តេង ច័ន្ទណារត** | អត្តលេខ | ៦៥២១២ |
| ៦- លោកវរសេនីយ៍ទោ | **អ៊ុំ សំអុល** | អត្តលេខ | ៦៨២៣១ ។ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៦ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥១ . អនុក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ហុង ណារ៉ុង** អត្តលេខ ៦៦៩៥៤

២- លោកវរសេនីយ៍ទោ **គុយ ញ៉ូន** អត្តលេខ ២៤៦៩៧

៣- លោកវរសេនីយ៍ទោ **ហុង រតនៈ** អត្តលេខ ៥៧៩៩៦ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៥០៥.....សហវ..ប្រក

រាជធានីភ្នំពេញថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣

# ប្រកាសអន្តរក្រសួង
# ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្ត
# ថវិកាកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា

************

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១០/នស/៩៤. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩ /១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /១២០៦/ ០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

-បានឃើញព្រះរាជក្រមលេខ នស/ រកម/១២០៦/០៣៥.ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០០៧

-បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

រដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ស្តីពីលទ្ធកម្មសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញសារាចរណែនាំលេខ០១៤សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញសារាចរលេខ ០១៦ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ស្តីពីការណែនាំលើការអនុវត្តថវិកាឆ្នាំ២០០៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានភារកិច្ចរៀបចំគម្រោង ផែនការថវិកាកម្មវិធី និងគម្រោងចំណាយថវិកាដើម្បីធានាឱ្យការចំណាយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ សំដៅលើកកម្ពស់គុណភាពនៃការ សិក្សាអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយសមធម៌ ជាពិសេស ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

## ជំពូកទី ២

## គោលការណ៍ចំណាយ

**ប្រការ ២.-**

គោលការណ៍ចំណាយដោយឡែក ត្រូវបានកំណត់ឱ្យអនុវត្តសម្រាប់ថវិកាកម្មវិធី ក្នុងការអភិវឌ្ឍន៍លើវិស័យអប់រំដូចខាងក្រោម :

**ក- គុណភាព និងប្រសិទ្ធភាពនៃការអប់រំកុមារតូច**

**១-ថវិកាដំណើរការសាលារៀន:**

១.១-សាលានៅតំបន់ធម្មតា:

១.១.១-សាលាមត្តេយ្យរដ្ឋមាន៣ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន៤០០.០០០រៀលក្នុងមួយសាលា និងសម្រាប់កុមារអាយុពី៣-៥ឆ្នាំចំនួន ៩.០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.១.២ -សាលាមត្តេយ្យរដ្ឋមាន៣ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន៤៥០,០០០រៀលក្នុងមួយសាលា និងសម្រាប់កុមារអាយុពី៣-៥ឆ្នាំចំនួន ៨,០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.២-សាលានៅតំបន់ដាច់ស្រយាល និង/ឬតំបន់ជួបការលំបាក:

១.២.១-សាលាមត្តេយ្យរដ្ឋមាន៣ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន៤៥០,០០០រៀលក្នុងមួយសាលា និងសម្រាប់កុមារអាយុពី៣-៥ឆ្នាំចំនួន១០,០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.២.២-សាលាមត្តេយ្យរដ្ឋមាន៣ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន៥០០,០០០រៀលក្នុងមួយសាលា និងសម្រាប់កុមារអាយុពី៣-៥ឆ្នាំចំនួន៩,០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា សម្រាប់ចំណាយលើ:

-សម្ភារមូលដ្ឋាន

-ការកែលម្អបរិស្ថាន សាលា និងថ្នាក់រៀន

-ការជួសជុលតូច ( សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )

-ចំណាយសម្រាប់ទឹកស្អាត និងអនាម័យ

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក:

+បញ្ចូលអាគុយ

+ទិញប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើង និងម៉ាស៊ីនបូមទឹក

+ទិញទឹកសម្រាប់ប្រើប្រាស់ ។ល។ (សក្ខីបត្រទូទាត់របស់រដ្ឋឬឯកជន តាមស្ថានភាពជាក់ស្តែង)

-ចំណាយផ្សេងៗ ។

**២-ថវិកាសម្រាប់ពង្រឹងគុណភាពរៀន និងបង្រៀនៈ**

ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំបច្ចេកទេស ប្រចាំសប្តាហ៍ ចំនួន១៤ ពេលក្នុងមួយឆ្នាំសិក្សា។

## ខ-គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

**១-ថវិកាដំណើរការសាលារៀន :**

១.១-សាលានៅតំបន់ធម្មតា:

១.១.១-សាលាបឋមសិក្សាមាន៦ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន៨០០,០០០រៀលក្នុងមួយសាលា និងចំនួន១០,០០០រៀលក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា

១.១.២-សាលាបឋមសិក្សាមាន៦ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន១,០០០,០០០រៀល ក្នុងមួយសាលា និងចំនួន៩,០០០រៀលក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.២-សាលានៅតំបន់ដាច់ស្រយាល និង/ឬតំបន់ជួបការលំបាក:

១.២.១-សាលាបឋមសិក្សាមាន៦ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន១,០០០,០០០រៀលក្នុងមួយសាលា និងចំនួន១២,០០០រៀលក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា

១.២.២-សាលាបឋមសិក្សាមាន៦ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន១,២០០,០០០រៀល ក្នុងមួយសាលា និងចំនួន១០,០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា សម្រាប់ចំណាយលើ :

-សម្ភារមូលដ្ឋាន

-ការជួសជុលតូច ( សង្ហារឹម បរិក្ខារ បណ្ណាល័យ និងអេឡិចត្រូនិច )

-ការទិញសៀវភៅអានដាក់ក្នុងបណ្ណាល័យ

-ការកែលម្អបរិស្ថានសាលា និងថ្នាក់រៀន

-បំណិនជីវិត ( កីឡា សិល្បៈ រោងជាង គេហវិជ្ជា កសិកម្ម )

-ចំណាយសម្រាប់ទឹកស្អាត និងអនាម័យ

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក:

+បញ្ចូលអាគុយ

+ទិញប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើង និងម៉ាស៊ីនបូមទឹក

+ទិញទឹកសម្រាប់ប្រើប្រាស់ ។ល។ ( សក្ខីបត្រទូទាត់របស់រដ្ឋឬឯកជនតាមស្ថានភាពជាក់ស្តែង)

-ការរៀបចំឯកសារធ្វើតេស្តចុងឆ្នាំសិក្សាសម្រាប់ថ្នាក់ទី ៣ និងទី៦

-ចលនាបីល្អ ( សិស្សល្អ មិត្តល្អ កូនល្អ ) របស់ក្រុមប្រឹក្សាកុមារ

-ចំណាយផ្សេងៗ ។

## ២-ថវិកាសម្រាប់ពង្រឹងគុណភាពរៀន និងបង្រៀន:

-ផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សពូកែប្រចាំឆ្នាំចំនួន ២០.០០០រៀល ក្នុងមួយថ្នាក់ក្នុងមួយឆ្នាំសិក្សា

-ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកម្រងសាលារៀន( ដើមឆ្នាំ កណ្តាលឆ្នាំ និងចុងឆ្នាំ) ចំនួន១១ពេលក្នុងមួយឆ្នាំសិក្សា

-ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍នៅតាមកម្រងឬសាលារៀននៅសប្តាហ៍ទី៤នៃខែ នីមួយៗចំនួន ០៧ពេលក្នុងមួយឆ្នាំសិក្សា

-ផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រូបង្រៀន ដែលបានបង្រៀនម៉ោងបន្ថែម សម្រាប់ជួយសិស្សនៅថ្ងៃព្រហស្បតិ៍ក្នុងឆ្នាំសិក្សា ។

ចំនួន ១២,០០០រៀល ក្នុងមួយពេលក្នុងមួយនាក់ ដោយគិតទាំងអ្នកគ្រប់គ្រង បណ្ណារក្ស រោងជាង និងលេខាធិការ ។

**គ-គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា**

**១-ថវិកាដំណើរការសាលារៀន :**

១.១-សាលានៅតំបន់ធម្មតា:

១.១.១-សាលាមាន១០ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន១.៥០០,០០០រៀលក្នុងមួយសាលា និងចំនួន១៩,០០០រៀលក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា

១.១.២-សាលាមាន១០ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន២,០០០,០០០រៀល ក្នុងមួយសាលា និងចំនួន១៧,០០០រៀល ក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.២-សាលានៅតំបន់ដាច់ស្រយាល និង/ឬតំបន់ជួបការលំបាក:

១.២.១-សាលាមាន១០ថ្នាក់ចុះ :

ផ្តល់ថវិកាចំនួន២,០០០,០០០រៀលក្នុងមួយសាលា និងចំនួន២១,០០០រៀលក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា

១.២.២-សាលាមាន១០ថ្នាក់ឡើង :

ផ្តល់ថវិកាចំនួន២.៥០០,០០០រៀល ក្នុងមួយសាលា និងចំនួន១៩,០០០រៀលក្នុងសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា

១.៣-អគារធនធាន:

ផ្តល់ថវិកាសម្រាប់ដំណើរការអគារធនធានចំនួន ៣៥.០០០.០០០រៀល ក្នុងមួយអគារ ក្នុងមួយឆ្នាំសិក្សា សម្រាប់ចំណាយលើ :

-សម្ភារមូលដ្ឋាន

-ការទិញសៀវភៅអានដាក់ក្នុងបណ្ណាល័យ

-ការកែលម្អបរិស្ថានសាលារៀន និងថ្នាក់រៀន

-ការជួសជុលតូច ( សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )

-បំណិនជីវិត ( កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម )

-ការរៀបចំឯកសារ និង សម្ភារផ្សេងៗ សម្រាប់ប្រឡងឆមាស

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក:

+បញ្ចូលអាគុយ

+ទិញប្រេងឥន្ទនៈសម្រាប់ម៉ាស៊ីនភ្លើង និងម៉ាស៊ីនបូមទឹក

+ទិញទឹកសម្រាប់ប្រើប្រាស់ ។ល ។( សក្ខីបត្រទូទាត់របស់រដ្ឋឬឯកជន តាមស្ថានភាពជាក់ស្តែង)

-ចលនាបីល្អ ( សិស្សល្អ មិត្តល្អ កូនល្អ) របស់ក្រុមប្រឹក្សាយុវជន

-ចំណាយផ្សេងៗ ។

**២-ថវិកាសម្រាប់ពង្រឹងគុណភាពរៀន និងបង្រៀន:**

-ផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សពូកែប្រចាំឆ្នាំចំនួន៥០.០០០រៀល ក្នុងមួយថ្នាក់ ក្នុងមួយឆ្នាំសិក្សា

-ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការប្រជុំក្រុមបច្ចេកទេសប្រចាំខែចំនួន០៧ពេលក្នុងមួយឆ្នាំសិក្សា។

**៚.បញ្ជាក់ :** តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ឃ-បន្តការអភិវឌ្ឍន៍គ្រូបង្រៀន**

**១**-ផ្តល់ថវិកាសម្រាប់ដំណើរការសាលារៀន ដល់សាលាគរុកោសល្យ និងវិក្រឹត្យការរាជធានី-ខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រាជធានី-ខេត្ត និងសាលាមធ្យមសិក្សាមត្តេយ្យមជ្ឈឹមចំនួន ៣៣,០០០,០០០រៀល ក្នុងមួយសាលាក្នុងមួយឆ្នាំ និងថវិកាសម្រាប់គរុសិស្សចំនួន១៣០.០០០រៀល ក្នុងគរុសិស្ស-និស្សិតមួយនាក់ក្នុងមួយឆ្នាំ សម្រាប់ចំណាយលើ :

-សកម្មភាពបង្រៀន និងរៀន

-សកម្មភាពអប់រំសីលធម៌ និងមនសិការវិជ្ជាជីវៈ

-សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ

-ការប្រជុំបច្ចេកទេស

-សកម្មភាពពលកម្មផលិត

-សកម្មភាពសិល្បៈ និងកីឡា

-សកម្មភាពស្រាវជ្រាវ

-សម្ភារមូលដ្ឋាន

-ការជួសជុលតូច

-ការដឹកជញ្ជូន និងការផ្គត់ផ្គង់សម្ភារ

-ចំណាយផ្សេងៗ

**២**-ផ្តល់ថវិកាជូនមជ្ឈមណ្ឌលធនធាននៅតាមរាជធានី-ខេត្តដែលគ្មានសាលាគរុកោសល្យនិងវិក្រឹត្យការចំនួន១៣,០០០,០០០រៀល ក្នុងមួយមជ្ឈមណ្ឌល ក្នុងមួយឆ្នាំសម្រាប់ចំណាយលើ:

-សម្ភារមូលដ្ឋាន

-ការជួសជុលតូច

-ការកសាងបរិស្ថាន និងការថែរក្សាអនាម័យ

-ចំណាយផ្សេងៗ

**៣**-ការរៀបចំឯកសារធ្វើតេស្ត សម្រាប់វាយតម្លៃសមត្ថភាពគ្រូឧទ្ទេសត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

| | | |
|---|---|---|
| - ការកសាងតេស្ត | ឧបត្ថម្ភ | ១០០,០០០រៀល/មុខវិជ្ជា |
| - ការធ្វើអត្រាកំណែ | ឧបត្ថម្ភ | ២០,០០០រៀល/នាក់ |

- កម្រែកែកិច្ចការ ឧបត្ថម្ភ ២,០០០រៀល/កិច្ចការ
- គណៈកម្មការបូកសរុបលទ្ធផល ឧបត្ថម្ភ ៥០,០០០រៀល/នាក់
- គណៈកម្មការត្រួតពិនិត្យ ឧបត្ថម្ភ ៣០,០០០រៀល/នាក់
- អ្នកធ្វើរបាយការណ៍ ឧបត្ថម្ភ ៣០,០០០រៀល/នាក់

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសេចក្តីណែនាំស្តីពីការកំណត់និយាមរៀបចំគណៈកម្មការនីមួយៗឱ្យបានច្បាស់លាស់ ក្នុងកម្រិតអប្បបរមា ។

## ខ_គុណភាព និងប្រសិទ្ធភាពនៃការអប់រំចំណេះទូទៅ និងបច្ចេកទេស

### ១-ថវិកាសម្រាប់ដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស :

ផ្តល់ថវិកាចំនួន៥០,០០០,០០០រៀល ក្នុងមួយសាលារៀនចំណេះទូទៅ និងបច្ចេកទេស និងចំនួន ៦០០.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សម្រាប់ចំណាយលើ:

-សម្ភារមូលដ្ឋាន

-ការជួសជុលតូច

-សម្ភារពិសោធន៍ កសិកម្ម រោងជាង អគ្គិសនី មេកានិច និងអេឡិចត្រូនិច

-ការកែលម្អបរិស្ថាន

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក :

+បញ្ចូលអាគុយ

+ទិញប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើង និងម៉ាស៊ីនបូមទឹក

+ទិញទឹកសម្រាប់ប្រើប្រាស់ ។ល។ (សក្តិបត្រទូទាត់របស់រដ្ឋឬឯកជន តាមស្ថានភាពជាក់ស្តែង)

-ចំណាយផ្សេងៗ

### ២-ថវិកាសម្រាប់ពង្រឹងគុណភាពរៀន និងបង្រៀនៈ

-ផ្តល់ថវិកាគាំទ្រសកម្មភាពចុះកម្មសិក្សា ឬដំណើរទស្សនកិច្ចសិក្សាដល់សិស្សចំនួន ៤០.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា

-ក្នុងករណីចាំបាច់ខ្វះគ្រូ ផ្តល់ថវិកាដល់ជូនគ្រូកិច្ចសន្យាចំនួន ៥០០.០០០រៀលក្នុងមួយនាក់ក្នុងមួយខែដែលត្រូវបង្រៀន ពី៤៨ម៉ោង-៥៦ម៉ោង ។

## គ_គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា

ផ្តល់ថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌល ឬសាលាចំនួន ៣៣.០០០.០០០រៀល ក្នុងមួយមជ្ឈមណ្ឌល ឬ មួយសាលា និងចំនួន ១៣០,០០០រៀល ក្នុងគរុសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សម្រាប់ចំណាយលើៈ

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពបច្ចេកទេស និងប្រកួត
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រកីឡា និង វេជ្ជសាស្ត្រកីឡា
- ចំណាយផ្សេងៗ ។

**ឆ-ការពង្រីកអប់រំក្រៅប្រព័ន្ធ :**

-ផ្តល់ថវិកាដល់មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់ចំនួន ១០,០០០,០០០រៀលក្នុងមួយឆ្នាំ

-ផ្តល់ថវិកាសម្រាប់ដំណើរការថ្នាក់បំប៉នសិស្សបោះបង់ការសិក្សាចំនួនពី១០០,០០០រៀល-១៥០,០០០រៀលក្នុងមួយថ្នាក់ក្នុងមួយឆ្នាំ ( ខែសីហា និងកញ្ញា) សម្រាប់ចំណាយលើសម្ភារសិក្សា

-ផ្តល់ថវិកាសម្រាប់សាលារៀនកម្មវិធីសមមូលចំនួន១៥០,០០០រៀល ក្នុងមួយសាលា និងចំនួន១១,០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំ សម្រាប់ចំណាយលើ:

+សម្ភារមូលដ្ឋាន

+សម្ភាររៀន និងបង្រៀន

+ការកែលម្អថ្នាក់រៀន

+ចំណាយផ្សេងៗ

-ផ្តល់ប្រាក់ម៉ោងបន្ថែមជូនគ្រូបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាអប់រំក្រៅប្រព័ន្ធ។

**ជ-គោលការណ៍រួម សម្រាប់អនុវត្តគ្រប់អង្គភាពដែលទទួលបានថវិកាកម្មវិធី:**

ការអនុវត្តថវិកាតាមកម្មវិធី និងការកសាងឯកសារបង្រៀន និងរៀនត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

**១-គោលការណ៍រួម:**

- ការថតចម្លងឯកសារដោយមិនប្រើសម្ភាររបស់រដ្ឋ ទូទាត់តាមតម្លៃជាក់ស្តែង

| | | | |
|---|---|---|---|
| - អ្នកគូររូប | ឧបត្ថម្ភ | ១៦,០០០រៀល | ក្នុង១ទំព័រ |
| - ការបកប្រែឯកសារ | ឧបត្ថម្ភ | ៤,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - អ្នកនិពន្ធ | ឧបត្ថម្ភ | ១៤,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យ | ឧបត្ថម្ភ | ១,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការរៀបរៀង និងចងក្រង | ឧបត្ថម្ភ | ៤,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការកែលម្អមេរៀន | ឧបត្ថម្ភ | ១២,០០០រៀល | ក្នុង១មេរៀន |

២_គោលការណ៍ដោយឡែកសម្រាប់អនុវត្តនៅតាមគ្រឹះស្ថានឧត្តមសិក្សា

| | | | |
|---|---|---|---|
| - ការបកប្រែឯកសារ | ឧបត្ថម្ភ | ១២,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - អ្នកនិពន្ធ | ឧបត្ថម្ភ | ២៨,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យ | ឧបត្ថម្ភ | ៤,០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការកែលម្អមេរៀន | ឧបត្ថម្ភ | ២០,០០០រៀល | ក្នុង១មួយមេរៀន |
| - ការជួលម៉ូដែល (Model) មនុស្សពិតមកធ្វើគំរូ សម្រាប់ឱ្យនិស្សិតគូរតាម | ឧបត្ថម្ភ | ៣០,០០០រៀល | ក្នុង១គំរូ ក្នុង១ពេល |

⊗ ចំពោះការទិញសម្ភារ និងឯកសារស្រាវជ្រាវផ្សេងៗពីបរទេស ត្រូវទូទាត់តាមសក្ខីប័ត្រជាក់ស្តែងតាមអត្រាប្តូរប្រាក់ជាផ្លូវការរបស់ធនាគារជាតិ ( ចំពោះតែសម្ភារ និងឯកសារណាដែលគ្មានលក់លើទីផ្សារក្នុងស្រុក ) ។

**ឈ_គុណភាពប្រសិទ្ធភាពការងារយុវជន**

ផ្តល់ថវិកាចំនួន ១០,០០០,០០០រៀលសម្រាប់មួយមជ្ឈមណ្ឌលយុវជនក្នុងមួយឆ្នាំ សម្រាប់ចំណាយលើៈ

-សម្ភារមូលដ្ឋាន

-ការជួសជុលតូច

-ការកែលម្អបរិស្ថាន

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក(សក្ខីបត្រទូទាត់របស់រដ្ឋឬឯកជន តាមស្ថានភាពជាក់ស្តែង)

-ចំណាយផ្សេងៗ ។

## ជំពូកទី ៣
## ការអនុវត្តថវិកាកម្មវិធី

**ប្រការ ៣._**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងផ្ទេរឥណទានថវិកាកម្មវិធីជូនទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ឥណទានថវិកាឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។ ចំពោះយន្តការដែលត្រូវអនុវត្តថវិកាកម្មវិធីមានដូចខាងក្រោមៈ

-ឥណទានថវិកា សម្រាប់ការចំណាយដំណើរការថ្នាក់រៀន មជ្ឈមណ្ឌលសិក្សាសហគមន៍ សាលារៀន គ្រឹះស្ថានសិក្សា អង្គភាព នាយកដ្ឋាន និងការចំណាយថវិកាកម្មវិធី ដែលមានគោលការណ៍កំណត់ច្បាស់លាស់ត្រូវអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានមួយរយភាគរយ( ១០០% ) ដោយមិនគិត១/៤លើ៣០ភាគរយ នៃឥណទានដែលជ្រើសរើសមកបង្កើតរដ្ឋទេយ្យបុរេប្រទាន នេះទេ ។

-រាល់ការចំណាយថវិកាដែលពាក់ព័ន្ធ ទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗ ដែលមានទឹកប្រាក់ក្រោម ២០លានរៀល ត្រូវអនុវត្តតាមលំនាំនីតិវិធីនៃវិធីសាស្ត្រលទ្ធកម្ម "ស្ទង់តម្លៃ" ។

**ប្រការ ៤.-**

ក្រោយពីមានប្រកាសអន្តរក្រសួង ស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងការបង្កើតរដ្ឋទេយ្យបុរេប្រទានរួច ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំបែបបទនៃការដកសាច់ប្រាក់រដ្ឋទេយ្យបុរេប្រទានដូចខាងក្រោមៈ

**-រដ្ឋបាលកណ្តាល :** ក្រសួងអប់រំ យុវជន និងកីឡា ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគារជាតិតែម្តង

**-រាជធានី-ខេត្ត :** មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគាររាជធានី-ខេត្តតែម្តង រួចរៀបចំបែងចែកសាច់ប្រាក់ជូនទៅគ្រឹះស្ថានសិក្សា និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង-ស្រុក-ខណ្ឌ ដើម្បីបើកផ្តល់ជូនសាលារៀន។

**ប្រការ៥.-**

នីតិវិធីនៃការទូទាត់រដ្ឋទេយ្យបុរេប្រទានត្រូវអនុវត្តតាមបរិបទដូចខាងក្រោមៈ

**-រដ្ឋបាលកណ្តាល :** គ្រប់អង្គភាពដែលអនុវត្តថវិកាតាមកម្មវិធី ត្រូវប្រមូលសក្ខីបត្រចំណាយ និងលិខិតយុត្តិការរៀបចំបោះផ្សាយអាណត្តិទូទាត់។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលអមផ្ទាល់នៅក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិពិនិត្យ និងចុះហត្ថលេខាលើអាណត្តិទូទាត់រដ្ឋទេយ្យបុរេប្រទានក្នុងនាមជាអភិបាលហិរញ្ញវត្ថុ បន្ទាប់មកបញ្ជូនទៅរតនាគារជាតិ។

**-រាជធានី-ខេត្ត :**

+ថ្នាក់រៀន មជ្ឈមណ្ឌលសហគមន៍ និងសាលារៀនត្រូវរៀបចំសក្ខីបត្រចំណាយ និងលិខិតយុត្តិការបញ្ជូនទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ ។ ការិយាល័យអប់រំក្រុង-ស្រុក-ខណ្ឌ ត្រូវត្រួតពិនិត្យឯកសារទាំងអស់ ឱ្យបានត្រឹមត្រូវ និងបូកសរុប រួចបញ្ជូនបន្តទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

+គ្រឹះស្ថាន ត្រូវរៀបចំប្រមូលសក្ខីបត្រចំណាយនិងលិខិតយុត្តិការបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ត្រូវពិនិត្យឱ្យបានត្រឹមត្រូវរាល់សក្ខីបត្រចំណាយ និងលិខិតយុត្តិការទាំងអស់ រួចរៀបចំបោះផ្សាយអណត្តិទូទាត់ និងចុះហត្ថលេខា ដោយអាណាប័កផ្ទេរសិទ្ធិ បន្ទាប់មកបញ្ជូនអាណត្តិទូទាត់នោះទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ពិនិត្យ និងចុះហត្ថលេខាក្នុងនាមជាអភិបាលហិរញ្ញវត្ថុមុននឹងបញ្ជូនទៅរតនាគាររាជធានី-ខេត្ត ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**ប្រការ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីការអនុវត្តថវិកាកម្មវិធី(PB) ឆ្នាំ២០១៤ តទៅ។

**ប្រការ៧.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។/

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**គាត ឈន់** **អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អាជ្ញាធរសវនកម្មជាតិ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៨ "ដើម្បីអនុវត្ត"

-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ៤៤៧ ...

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ៣៣២ /១៣ គ.វ.ក ចុះថ្ងៃទី១៨.០២.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ភែតថិន អ៊ិនធើណេសិនណាល (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី០៨.០២.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ភែតថិន អ៊ិនធើណេសិនណាល (ខេមបូឌា) ខមភេនី លីមីធីត ( PATTERN INTERNATIONAL (CAMBODIA) COMPANY LIMITED) តំណាងដោយ លោក ZHANG TINGJIN សញ្ជាតិចិន អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G44247443 ចុះថ្ងៃទី៣០.០៧.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ 701-71F, Tower2, Silvercord, 30 Canton Road, Tsim Sha Tsui, Kowloon, Hong Kong [illegible] ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 Fax : 855-23-428263

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

- **ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រកាត់ដេរសម្លៀកបំពាក់ កែតថិន អ៊ិនធើណេសិនណល (ខេមបូឌា) ខមភេនី លីមីធីត* "
- **ទីតាំងរោងចក្រ ៖** " *ផ្លូវជាតិលេខ៤ ភូមិវំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៤២៥ ឧរថ.គនុ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៩៧៩/១២ គ.ស.ព ចុះថ្ងៃទី២៨.០៨.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុនអូជីតិច ហាតា ភែកឃិជីង(សីហនុវីល) លីមីធីត ចុះថ្ងៃទី២៣.០៧.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អូជីតិច ហាតា ភែកឃិជីង (សីហនុវីល) លីមីធីត (OJITEX HARTA PACKAGING (SIHANOUKVILLE) LIMITED.) តំណាង ដោយ លោក CHAN CHOR NGIAK សញ្ជាតិម៉ាឡេស៊ី អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A27639424 ចុះថ្ងៃទី ១៧.១០.២០១២ មានអាសយដ្ឋានបច្ចុប្បន្នៈ 1JALAN KERIS NAGA TMN PASIFIK SELATAN 83000 BT PAHAT, JOHOR. ជាម្ចាស់រោងចក្រ បង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កេសកាតុង | ១៧០២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh Phone : 855-23-211141 , Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រផលិតកេសកាតុងអូជីគិច ហាគា តែកយិជីង (ស៊ីហានុវីល) លីមីធីត "*

**-ទីតាំងរោងចក្រ ៖** *" ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (ភូមិ៣ សង្កាត់លេខ៣ និងភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ)"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណាងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៧០០/០៥ គ.វ.ក ចុះថ្ងៃទី០៣.០៣.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ចុះថ្ងៃទី០៨.០១.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) (SL GARMENT PROCESSING (CAMBODIA) LTD.) តំណាងដោយ លោក WONG HON MING សញ្ជាតិសិង្ហបុរី អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E0852338H ចុះថ្ងៃទី០៧.០៧.២០០៨ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

ផ្លាករឈ្មោះរោងចក្រ ៖ " *រោងចក្របោកកក់សម្លៀកបំពាក់ អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា)* "

**ទីតាំងរោងចក្រ ៖** " *ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** ប្រកាសលេខ ១៩៩ ឧរថ.កឧ.ប្រក. ចុះថ្ងៃទី២៨.០៣.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្របោកគក់សម្លៀកបំពាក់ នាំចេញ របស់ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ